**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**
សំណុំរឿងព្រហ្មទណ្ឌលេខ:១៩៣
ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ

**សាលក្រមព្រហ្មទណ្ឌ**
លេខ: ១៧ (ច)
ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៨

*សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៨ ។*

*ដោយមានសមាសភាព:*

១-លោក [redacted] *ប្រធានក្រុមប្រឹក្សាជំនុំជម្រះ*
២-លោក [redacted] *ចៅក្រមប្រឹក្សា*
៣-លោកស្រី [redacted] *ចៅក្រមប្រឹក្សា*
៤-លោក [redacted] *តំណាងអយ្យការ*
៥-លោក [redacted] *ក្រឡាបញ្ជីសវនាការ*

*<u>ដើម្បីជំនុំជម្រះលើជនជាប់ចោទ:</u>*

១-ឈ្មោះ:[redacted]ភី ភេទប្រុស អាយុ ៨៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ:[redacted]ស) ម្តាយឈ្មោះ:[redacted](ស) ប្រពន្ធឈ្មោះ: [redacted]) មានកូន ០៦នាក់ ទោសពីមុនគ្មាន។

ត្រូវជាប់ចោទពីបទ: រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅភូមិចារថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។

ដោយមានលោក[redacted]ពិសី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ:[redacted] ភី ។

និងដោយមានលោកមេធាវី[redacted]ប៊ុនហេង ការពារសិទ្ធិឲ្យជនរងគ្រោះ ។

### ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៧ វេលាម៉ោង ១០ព្រឹក នៅចំណុចព្រៃក្រោយផ្ទះរបស់ឈ្មោះ[redacted]ម៉ាក់ ស្ថិតនៅភូមិចារថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានករណី រួមភេទជាមួយអនីតិជនអាយុក្រោម



Scanned by CamScanner

១៥ឆ្នាំ ដែលបង្កឡើងដោយឈ្មោះ [redacted] ភី បានរំលោភក្មេងស្រីឈ្មោះ [redacted] រចនា អាយុ ១៣ឆ្នាំ នៅពេលជនរងគ្រោះទៅបត់ជើងនៅព្រៃក្រោយផ្ទះ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ២៧៨ /១៧ ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ ។

បានឃើញ ដីកាចាត់តាំងចៅក្រមប្រឹក្សាជំនុំជម្រះលេខៈ ១០១៥ /១៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៧ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] ភី បានឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ ក្នុងឆ្នាំ ២០១៦ ខ្លួនបានដើរនៅតាមថ្នល់ ពេលនោះមានក្មេងស្រីឈ្មោះ រចនា បក់ដៃហៅខ្លួន និងសួរខ្លួនថាស្រឡាញ់វាឬអត់ មិនត្រឹមតែប៉ុណ្ណោះវាបានបបួលគ្នារួមរក្សទៀតផង ពេលនោះខ្លួនបានបណ្ដើរឈ្មោះ រចនា ទៅក្នុងព្រៃ ដំបូងខ្លួនស្រាតខោរួចអង្គុយ និងឲ្យឈ្មោះ រចនា អង្គុយលើដោយដាក់ចូ [redacted] លុះពេលរួមរក្សហើយពុំមានចេ [redacted] ឡើយ ព្រោះគ្រាន់តែចូលបន្តិចតែប៉ុណ្ណោះ ចំណែកលើកទីពីរនៅក្នុងព្រៃដដែលដោយណាត់ជួបគ្នា និងបានរួមរក្សគ្នាដូចលើកមុនដែរ ខ្លួនពុំបានចាប់បង្ខំ គម្រាមកំហែងអ្វីនោះទេ ។

-ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ាក់ បានឆ្លើយថាៈ ខ្លួនពុំបានឃើញរឿងហេតុផ្ទាល់ទេ ខ្លួនសុំទាមទារជម្ងឺចិត្តចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។

-ចម្លើយជនរងគ្រោះឈ្មោះ [redacted] រចនា បានឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ ខ្លួនទៅបត់ជើងនៅក្នុងព្រៃ ព្រោះបន្ទប់ទឹកខូច ពេលនោះឈ្មោះ [redacted] ភី ដើរមកពីក្រោយខ្លួន និងចាប់បីខ្លួន ព្រមទាំងស្រាតខោ រួចគាត់ក៏ប្រលេះទ្បេវខោគាត់ [redacted] ប៉ុន្តែខ្លួនឈឺ ហើយគាត់ក៏ដកវិញ និងបានគម្រាមកំហែងនឹងសម្លាប់ បើខ្លួនប្រាប់ទៅនរណាម្នាក់ ចំណែកលើកទីពីរខ្លួនទៅឃ្វាលគោ ហើយបានជួបនឹងឈ្មោះ [redacted] ភីទៀត ហើយគាត់បាននៅពីលើខ្លួន ហើយប្រឡេះឡេវខោ រួចយកប្រដាប់ភេទគាត់ ដាក់ចូលប្រដាប់ភេទខ្លួនដូចលើកមុន ខ្លួនពុំបានស្រឡាញ់គាត់ឡើយ ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] សុខ បានឆ្លើយថាៈ កាលពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខ្លួនបានយកត្រីទៅជូនម្ដាយក្មេកឈ្មោះ [redacted] សុង ស្រាប់តែឃើញគាត់យំ ពេលនោះខ្លួនសួរគាត់ថា ម៉ែឯងមានរឿងអី គាត់ប្រាប់ថាអាភី ចាប់រំលោភសេពសន្ថវៈ មីឌីណា ហើយកូនឯងជួយគិតម៉ែផង ពេលនោះខ្លួនប្រាប់គាត់ថាមានតែហៅប្ដីខ្លួនមកទេ រួចហើយខ្លួនក៏ជិះម៉ូតូទៅតាមប្ដីនៅកន្លែងដឹកកណ្ដាប់ ក្រោយពីប្ដីខ្លួនគាត់ដឹងរឿងហេតុហើយ គាត់ក៏នាំកូនស្រីទៅប្ដឹងនគរបាលអណ្ដូងស្នាយ ខ្លួនមិនបានឃើញរឿងហេតុផ្ទាល់ភ្នែកទេ។

-ចម្លើយសាក្សីឈ្មោះ [redacted] សម្បត្តិ បានឆ្លើយថាៈ ខ្លួនពុំបានឃើញហេតុការណ៍អ្វីឡើយ ខ្លួនគ្រាន់តែលឺប្ដីរបស់ខ្លួនស្រែកហៅឈ្មោះ រចនា ជាញឹកញាប់ខ្លួនក៏ទៅហាម តែប្ដីរបស់ខ្លួនបានប្រាប់ថាឈ្មោះ រចនា ក៏ជាប្រពន្ធរបស់គាត់ដែរ ។



Scanned by CamScanner

-កម្លើយសាក្សីឈ្មោះ[redacted] សំ បានឆ្លើយថាៈ ខ្លួនពុំបានឃើញហេតុការណ៍អ្វីឡើយ គ្រាន់តែខ្លួនមានការសង្ស័យថាបានហាមចៅស្រីខ្លួនមិនឲ្យទៅលេងផ្ទះឈ្មោះ [redacted] ភី ទៀត ពេលនោះខ្លួនក៏ទៅសួរចៅខ្លួន ហើយចៅខ្លួនក៏ស្រែកយំ ហើយពេលខ្លួនគម្រាមវាទើបវាប្រាប់ថាឈ្មោះ[redacted]ភី ចាប់រំលោភចំនួនពីរដង ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ភី ពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់។

-មេធាវីដើមបណ្តឹងបានធ្វើសេចក្តីសន្និដ្ឋានថាៈ មានភស្តុតាងដែលបញ្ជាក់ថាជនជាប់ចោទពិតជាបានរួមភេទជាមួយកូនក្តីខ្លួនពិតប្រាកដមែន ដូចគ្នាទៅនឹងចម្លើយកូនក្តីខ្លួន សូមឲ្យតុលាការមេត្តាផ្តន្ទាទោសឲ្យបានធ្ងន់ធ្ងរ និងសូមឲ្យសម្រេចលើសំណង ។

-មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថាៈ ឆ្លងតាមការសួរដេញដោលក្នុងអង្គសវនាការ បានបង្ហាញថាការរួមរក្សនេះពុំមានការចាប់បង្ខំឡើយ សូមឲ្យតុលាការផ្តល់ស្ថានសម្រាល ។

-ជនជាប់ចោទបានសំណូមពរចុងក្រោយថាៈ សូមឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ
ក្រោយពីបានស្តាប់ចម្លើយសាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
ក្រោយពីបានស្តាប់សំណូមពរចុងក្រោយ
ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **សាលាដំបូងខេត្តកំពង់ឆ្នាំង យល់ឃើញថាៈ**

១-តុលាការបានទទួលបណ្តឹង តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ២៧៤ /១៧ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភី មកតុលាការដើម្បីជំនុំជម្រះពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅភូមិចាថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។

២-ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ម៉ាក់ បានឆ្លើយថាៈ នៅក្នុងរឿងនេះខ្លួនសូមទាមទារជម្ងឺចិត្តចំនួន ២០.០០០.០០០(ម្ភៃលាន) រៀល ។



Scanned by CamScanner

៣-ចម្លើយជនជាប់ចោទឈ្មោះ [redacted] ភី បានឆ្លើយថាៈ ខ្លួនពិតជាបានរួមរក្សជាមួយឈ្មោះ រចនា ពិតប្រាកដមែនចំនួនពីរដង ប៉ុន្តែខ្លួនពុំបានបង្ខិតបង្ខំ ឬគម្រាមកំហែងឡើយ ការរួមរក្សនោះកើតឡើងពីការស្មគ្រចិត្តរវាងខ្លួន និងឈ្មោះ រចនា តែប៉ុណ្ណោះ ។

៤-ចម្លើយជនរងគ្រោះឈ្មោះ[redacted]ចនា បានឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ ឈ្មោះ [redacted] ភី បានចាប់បីខ្លួន និងស្រាតខោខ្លួន រួមយកប្រដាប់ភេទគាត់ ដាក់ចូលប្រដាប់ភេទរបស់ខ្លួន តែដោយខ្លួនមានការឈឺចាប់ គាត់ក៏ដកចេញ រួចបានគម្រាមកំហែងខ្លួននឹងសម្លាប់ បើប្រាប់ទៅនរណាម្នាក់ ហើយលើកទីពីរគាត់បានរួមរក្សដូចលើកមុន នៅកន្លែងឃ្វាលគោ ខ្លួនពុំបានស្រឡាញ់ឈ្មោះ[redacted] ភី ។

៥-ចម្លើយសាក្សីឈ្មោះ [redacted]សុខ [redacted] សំ និងឈ្មោះ[redacted]សម្បត្តិ បានឆ្លើយប្រហាក់ប្រហែលគ្នាថាៈ នៅក្នុងហេតុការណ៍នេះខ្លួនពុំបានឃើញដោយផ្ទាល់ទេ ។

៦-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានស្នើសុំថាៈ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ភី ពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ។ការប្តឹងសុំរបស់តំណាងអយ្យការ តុលាការអាចពិចារណាបាន នាពេលសវនាការជនរងគ្រោះពុំអាចផ្តល់ចម្លើយជាក់លាក់មកដល់អង្គសវនាការឡើយ ប៉ុន្តែតុលាការពិចារណាឃើញថាចម្លើយគ្រប់ដំណាក់កាលមានលក្ខណៈដូចគ្នាទៅនឹងចម្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ដែលបានបង្ហាញថាជនជាប់ចោទពិតជាមានរួមរក្សជាមួយនឹងជនរងគ្រោះ ក្នុងលក្ខខណ្ឌដែលជនរងគ្រោះស្ថិតក្នុងវ័យអនីតិជនប្រាកដមែន ដូច្នេះគប្បីតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៧-មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថាៈ ឆ្លងតាមការសួរដេញដោលក្នុងអង្គសវនាការ បានបង្ហាញថា ការរួមរក្សនេះពុំមានការចាប់បង្ខំឡើយ សូមឲ្យតុលាការផ្តល់ស្ថានសម្រាល ។ការស្នើសុំនេះតុលាការមិនអាចពិចារណាបានឡើយ ព្រោះការសួរដេញដោលក្នុងអង្គសវនាការ និងភស្តុតាងនានាបានបញ្ជាក់យ៉ាងច្បាស់ថាជនជាប់ចោទពិតជាបានរួមរក្សជាមួយជនរងគ្រោះ ដោយជនរងគ្រោះស្ថិតក្នុងវ័យអនីតិជននៅឡើយ ដូច្នេះគប្បីតុលាការពិចារណាតាមច្បាប់ ។

៨-មេធាវីដើមបណ្តឹងបានធ្វើសេចក្តីសន្និដ្ឋានថាៈ មានភស្តុតាងដែលបញ្ជាក់ថាជនជាប់ចោទពិតជាបានរួមភេទជាមួយកូនក្តីខ្លួនពិតប្រាកដមែន ដូចគ្នាទៅនឹងចម្លើយកូនក្តីខ្លួន សូមឲ្យតុលាការមេត្តាផ្តន្ទាទោសឲ្យបានធ្ងន់ធ្ងរ និងសូមឲ្យសម្រេចលើសំណង ។ ការស្នើសុំនេះ តុលាការនឹងផ្អែកតាមការខូចខាត ប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះតាមស្ថានភាពជាក់ស្តែង ចំណែកការផ្តន្ទាទោស តុលាការនឹងពិចារណាតាមច្បាប់ ។

៩-ឆ្លងកាត់ការសួរដេញដោលក្នុងសវនាការ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ការស្នើសុំរបស់មេធាវី តុលាការពិចារណាបានថា នៅថ្ងៃកើតហេតុជនជាប់ចោទពិតជាបានរួមរក្សជាមួយជនរងគ្រោះក្នុងវ័យអនីតិជនអាយុក្រោម ១៥ ឆ្នាំ ព្រោះបើយោងតាមចម្លើយជនរងគ្រោះ និងសាក្សីទោះមិនបានឃើញហេតុការណ៍ ប៉ុន្តែជនជាប់ចោទបានឆ្លើយសារភាពបានរួមរក្ស ទៅលើជនរងគ្រោះ ក្នុងលក្ខខណ្ឌដែលជនរងគ្រោះស្ថិតក្នុងវ័យក្រោម ១៥ ឆ្នាំ នៅឡើយដែលការប្រព្រឹត្តរបស់ជនជាប់ចោទដែលរួមភេទទៅលើអនីតិជន មានធាតុផ្សំទៅនឹងអំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ។



Scanned by CamScanner

១០-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទ:

-ឈ្មោះ [redacted]ភី ភេទប្រុស អាយុ ៤៨ ឆ្នាំ ។

ពីបទ: រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅភូមិចារថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។

១២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ាក់ ទាមទារសំណងជម្ងឺចិត្តចំនួន ២០.០០០.០០០(ម្ភៃលាន) រៀល គប្បីតុលាការពិចារណាលើភាពសមរម្យ នៃព្យសនកម្ម ។

១៣-ជនជាប់ចោទជានីតិជន ដែលមានភស្តុតាងឬសញ្ញាណបញ្ជាក់ថាកើតមានវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននេះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌលើអំពើប្រព្រឹត្តរបស់ខ្លួន អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម របៀបរៀបរយសាធារណៈ គោលនយោបាយភូមិឃុំ សុវត្ថិភាព និងបំពានច្បាប់។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទ:

ឈ្មោះ [redacted]ភី ភេទប្រុស អាយុ ៤៨ ឆ្នាំ ជាប់ពន្ធនាគារចំនួន ០៥ (ប្រាំ) ឆ្នាំ ។

ពីបទ: រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅភូមិចារថ្មី ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។

២-បង្គាប់ឲ្យជនជាប់ចោទសងសំណងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀលការទាមទារលើសពីនេះតុលាការច្រានចោល ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ភី ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ម៉ាក់ និង ជនរងគ្រោះឈ្មោះ [redacted]រចនា ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ស្មៀនក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted] [redacted] [redacted] [redacted]



Scanned by CamScanner